# គោលនយោបាយរបស់ស្ថាប័ន GCCF ស្ដីអំពីការរៀបចំពាក្យបណ្ដឹងទាមទារសំណង និងថ្លៃឈ្នួលប៉ាន់ប្រមាណ

ចំពោះពាក្យបណ្ដឹងទាមទារសំណងខ្លះ ដែលទទួលបាននូវការទូទាត់សំណងទៅលើការខូចខាតរួចហើយ ស្ថាប័ន GCCF នឹងធ្វើការទូទាត់នូវតម្លៃសមរម្យណាមួយ ដែលបានទទួលរងដោយសារអ្នកទាមទារសំណងចំពោះការប៉ាន់ប្រមាណទៅលើការខូចខាតដែលបានដាក់ប្ដឹងទាមទារនោះផងដែរ។ ស្ថាប័ន GCCF នឹងបូកបញ្ចូលនូវតម្លៃសមរម្យនៃការខូចខាតដែលប៉ាន់ស្មានទៅក្នុងការទូទាត់សំណងរបស់ខ្លួន។ ការទូទាត់សំណងទាំងនេះនឹងមិនបូកបញ្ចូលនូវការទូទាត់ទៅលើថ្លៃឈ្នួលរបស់មេធាវីទេ។ ស្ថាប័ន GCCF នឹងចាត់ការទៅលើពាក្យបណ្ដឹងទាមទារសំណងចំពោះតម្លៃទាំងនេះ ("តម្លៃប៉ាន់ប្រមាណ") ដូចខាងក្រោម:

1. <u>ឯកសារដែលតម្រូវអោយមានដោយស្ថាប័ន GCCF</u>។ ចំពោះពាក្យបណ្ដឹងទាមទារសំណងខ្លះ ដែលស្ថាប័ន GCCF មិនទាន់បានចេញលិខិតសម្រេចចុងក្រោយទៅអោយ អ្នកទាមទារសំណងម្នាក់ៗ ដែលកំពុងស្វែងរកការទូទាត់សំណងទៅលើតម្លៃប៉ាន់ប្រមាណត្រូវតែផ្ញើច្បាប់ចម្លងនៃ:

   (a) ឯកសារណាមួយ ដែលឆ្លុះបញ្ចាំងអោយកិច្ចសន្យា ឬកិច្ចព្រមព្រៀងណាមួយរវាងអ្នកទាមទារសំណង និងបុគ្គល ឬអង្គភាព ដែលបង់ថ្លៃទៅលើតម្លៃប៉ាន់ប្រមាណ ("អ្នករៀបចំពាក្យបណ្ដឹង") ហើយមានការពាក់ព័ន្ធទៅនឹងមធ្យោបាយណាមួយទៅនឹងពាក្យបណ្ដឹងទាមទារសំណង ដែលបានផ្ញើមកស្ថាប័ន GCCF;

394743
10/12/11

(b) វិក្កយប័ត្រមួយចំនួនសម្រាប់អ្នកទាមទារសំណងទៅលើពាក្យបណ្តឹងទាមទារសំណងនូវតម្លៃប៉ាន់ប្រមាណ និង

(c) កំណត់ត្រាពេលវាលា ដែលបង្ហាញពីពេលវេលាដែលបានចំណាយ និងសកម្មភាពបានធ្វើក្នុងការរៀបចំពាក្យបណ្តឹងទាមទារសំណង ដែលបង្កើតបានជាមូលដ្ឋានសម្រាប់តម្លៃប៉ាន់ប្រមាណដែលបានដាក់ប្តឹង។ ប្រសិនបើតម្លៃប៉ាន់ប្រមាណត្រូវបានផ្អែកទៅលើថ្លៃឈ្នួលកែតម្រូវ ឬការថ្លៃឈ្នួលធម្មតាជាជាងផ្អែកទៅលើអត្រាពេលវាលា នោះការបកស្រាយលំអិតពីការងារត្រូវបានធ្វើឡើងដោយអ្នករៀបចំពាក្យបណ្តឹងទាមទារសំណងសម្រាប់ពាក្យបណ្តឹង ដែលបានលើកឡើងចំពោះតម្លៃប៉ាន់ប្រមាណសម្រាប់ដាក់ប្តឹង។

ស្ថាប័ន GCCF នឹងមិនទូទាត់សងចំពោះតម្លៃប៉ាន់ប្រមាណណាមួយ ដែលមិនបានចង្អុលបង្ហាញនូវភស្តុតាងដោយឯកសារតម្រូវអោយមានទាំងនេះឡើយ។

2. <u>ទម្រង់ពាក្យបណ្តឹងទាមទារសំណងតាមរយៈបណ្តាញអ៊ីនធើណែត</u> ។

អ្នកទាមទារសំណងត្រូវតែចុះហត្ថលេខានៅលើទម្រង់ពាក្យបណ្តឹងទាមទារសំណង ដែលបានផ្ញើទៅស្ថាប័ន GCCF។ ទម្រង់ពាក្យបណ្តឹងទាមទារសំណង ដែលបានផ្ញើតាមបណ្តាញអ៊ីនធើណែតត្រូវតែមានភ្ជាប់មកជាមួយនូវហត្ថលេខាអេឡិចត្រូនិចរបស់អ្នកទាមទារសំណង។ អ្នករៀបចំពាក្យបណ្តឹងទាមទារសំណងមិនអាចចុះហត្ថលេខានៅលើទម្រង់ពាក្យបណ្តឹងទាមទារសំណងតំណាងអោយអ្នកទាមទារសំណងទេ។ ដូច្នេះ ស្ថាប័ន GCCF នឹងមិនបន្តអនុញ្ញាតអោយអ្នករៀបចំពាក្យបណ្តឹងទាមទារសំណងផ្ញើទម្រង់ពាក្យបណ្តឹងទាមទារសំណងតាមរយៈបណ្តាញអ៊ីនធើណែតទៀតទេ។ អ្នកទាមទារសំណងអាចផ្ញើទម្រង់ពាក្យបណ្តឹងទាមទារសំណងតាមរយៈបណ្តាញអ៊ីនធើណែត ឬអាចចុះហត្ថលេខានៅលើច្បាប់ចម្លងនៃទម្រង់ពាក្យបណ្តឹងទាមទារសំណង ហើយផ្ញើវាមកស្ថាប័ន GCCF។

3. <u>**សេចក្តីជូនដំណឹង និងការទូទាត់សំណង។**</u> ស្ថាប័ន GCCF នឹងមិនបន្តអោយមានការផ្ញើលិខិតសម្រេចទៅលើពាក្យបណ្តឹងទាមទារសំណង ឬទូទាត់សំណងទៅអោយអ្នករៀបចំពាក្យបណ្តឹងទាមទារសំណងទៀតទេ។ ជំនួសមកវិញ ស្ថាប័ន GCCF នឹងផ្ញើរាល់លិខិត និងរាល់ការទូទាត់ទាំងអស់ទៅអោយអ្នកទាមទារសំណងដោយផ្ទាល់។ ប្រសិនបើអ្នកទាមទារសំណងបានផ្ញើឯកសារមានចុះហត្ថលេខាដោយអ្នកទាមទារសំណងអោយមានការផ្តល់សិទ្ធិអនុញ្ញាតទៅអោយអ្នករៀបចំពាក្យបណ្តឹងទាមទារសំណងដើម្បីទទួលបានព័ត៌មានស្តីពីពាក្យបណ្តឹងទាមទារសំណងរបស់អ្នកទាមទារសំណងមកស្ថាប័ន GCCF នោះស្ថាប័ន GCCF នឹងផ្ញើច្បាប់ចម្លងនៃលិខិតនីមួយៗមកអោយអ្នករៀបចំពាក្យបណ្តឹងទាមទារសំណងនោះ។